# ការសំភាសន៍របស់អ៊ំស្រី ប៊ី ចាន់មុំ

កៈ អ្នកសំភាសន៍ឈ្មោះ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ ប៊ី ចាន់មុំ

## ការសង្ខេបរបស់អ៊ំស្រី ប៊ី ចាន់មុំ

អ៊ំស្រីប៊ី ចាន់មុំគឺជាស្ត្រីម្នាក់ដែលមានជីវិតដ៏សែនពិបាកហើយគាត់បានចាកចេញពីម្តាយរបស់គាត់តាំងពីនៅក្មេងដោយសារគាត់នឹងម្តាយគាត់រស់នៅជាមួយគ្នាមិនបានដោយសារពួកគាត់ឆុងគ្នាបើជិតគ្នាគឺឈឺ ចឹងទើបធ្វើអោយគាត់ត្រូវនៅបែកពីគ្នា។ហើយគាត់បានឆ្លងសង្រ្គាមក៏សែនពិបាកដោយសារអត់មានអង្ករដាំបាយហើយអត់ឃ្លានគាត់បានទៅលួចបុកអង្ករហើយប៉ុល ពតបានចាប់ទាន់ហើយគាត់បំរុងយកគាត់ទៅសម្លាប់តែដោយសារពូរបស់គាត់បានបោកគេថាគាត់ឆ្កួតទើបធ្វើអោយ គាត់បានរួចខ្លួនវិញ។

កៈ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ៊ំស្រីដែលអោយញ៉ុមសំភាសន៍អំពីនៃជីវិតរបស់អ៊ំនៅក្នុងថ្ងៃហ្នឹងហើយញ៉ុមឈ្មោះញ៉ែម សុគន្ធាជាអ្នកសំភាសន៍ហើយពួកយើងសំភាសន៍គឺនៅក្នុងថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧ ។ហើយការសំភាសន៍របស់ពួកយើងគឺត្រូវបានធ្វើឡើងនៅភូមិ អ៊ំរាល់ថ្ងៃអ៊ំនៅភូមិឃុំអីគេដែរ?

ខៈ ភូមិណែភូមិនេះភូមិវាល សង្កាត់គោកចក។

កៈ ចាំស្រុកអីខេត្តអីដែរអ៊ំ?

ខៈ ខេត្តសៀមរាប។

កៈ ស្រុកសៀមរាបខេត្តសៀមរាបហោ៎?

ខៈ ចាំ!!ញ៉ុមដឹងថាភូមិវាលសង្កាត់គោកចក។

កៈ ចាំហ្នឹងហើយអត់អីទេអ៊ំ!!!ចឹងអ៊ំ អ៊ំឈ្មោះពេញឈ្មោះអីគេដែរអ៊ំ?

ខៈ ប៊ី ចាន់មុំ។

កៈ ប៊ី ចាន់មុំ !!ចឹងអ៊ំមានឈ្មោះហៅខាងក្រៅអត់?

ខៈ ឈ្មោះហៅខាងក្រៅហ្នឹងហោ?

កៈ ចាំ!!!

ខៈ ហៅប៊ី ចាន់មុំហ្នឹង។

កៈ ប៊ី ចាន់មុំ !!ចឹងដូចជាពីក្មេងមកគេមានដាក់ងារអីអោយទេ?

ខៈ ប៊ី ចាន់មុំហ្នឹងតែមួយហ្នឹងឯង។

កៈ  តែមួយហ្នឹងគេហៅស្រីមុំៗចឹងទៅ?

ខៈ ចាំ!!!ចាំហ្នឹងហើយចឹងពីក្មេងមកម្ដាយរបស់អ៊ំដាក់ ឈ្មោះប៊ី ចាន់មុំហ្នឹងតែម្ដង?

ខៈ ចាំ!!

កៈ ហ្នឹងហើយចឹងតើក្នុងឆ្នាំនេះអ៊ំមានអាយុប៉ុន្មានហើយ?

ខៈ ៥០ប៉ុន្មានហើយ !!ដឹងតែ៥០ជាងតែអត់ចាំច្បាស់!!

កៈ ចាំ!!

ខៈ ដឹងតែ៥០ជាង។

កៈ ប្រហែលជា៥០ក្រាស់ ឬក៏៥០ស្ដើង?

ខៈ ប្រហែលជា៥០ស្ដើងទេ មិនទាន់៥០ក្រាស់ទេ ព្រោះម៉ែញ៉ុមទឹមតែអាយុ៨០ជាង។

កៈ ចាំ!!

ខៈ ម៉ែញ៉ុមចាស់ជរាហើយនៅភ្នំពេញអាយុ៨០ជាង។

កៈ ចាំចឹងអ៊ំអាយុ៥០ណោះ?

ខៈ កូនអីបងអីអត់មានទេស្លាប់បាត់អស់ហើយ នៅតែញ៉ុមហើយនឹងម៉ែ ឪក៏ស្លាប់ដែរ!!

កៈ ចាំ!!

ខៈ ឪស្លាប់អស់ហើយ។

កៈ ចឹងអ៊ំកើតនៅក្នុងឆ្នាំណាដែរថ្ងៃខែឆ្នាំណាដែរ?

ខៈ អត់សូវចាំ។

ក៖ ប្រហែលជាស្មានចឹងហាំអ៊ំ!!!

ខ៖ ដឹងតែថ្ងៃ។

ក៖ ថ្ងៃអីគេវិញអ៊ំ។

ខ៖ ដឹងតែថ្ងៃ ថ្ងៃព្រហស្បត៏។

ក៖ ចាំខែបារាំងខ្មែរអីចាំទេ?

ខ៖ អត់ចាំទេ។

ក៖ ចុះឆ្នាំខ្មែរកក្កិក ភទ្របទអីនោះអ៊ំកើតខែអីគេវិញ?

ខ៖ វាមិនចាំគាត់អត់បានប្រាប់ទេ។

ក៖ ហ្នឹងហើយ។

ខ៖ ញ៉ុមដឹងតែថ្ងៃ ថ្ងៃមួយហ្នឹង។

ក៖ ចឹងអ៊ំតើអ៊ំកើតនៅភូមិឃុំអីគេដែរ?កន្លែងកំណើតហាំ!!!!

ខ៖ តាកែវ។

ក៖ ខេត្តតាកែវហោំ?

ខ៖ សង្កាត់ព្រៃកប្បាស។

ក៖ ព្រៃកប្បាសហ្នឹងហើយ។

ខ៖ ខេត្តតាកែវ ហ្នឹងស្រុកកំណើត។

ក៖  ចឹងស្រុកកំណើតអ៊ំនៅខេត្តតាកែវហ្នឹង!!!ហ្នឹងហើយចឹងតើអ៊ំស្រីមានបងប្អូនប្រុសស្រីចំនួនប៉ុន្មាននាក់ដែរ?

ខ៖ បងប្អូន បងប្រុសបង្កើតម៉ងហោ?

ក៖ ចាំ!!

ខ៖ បងបង្កើតស្លាប់បាត់ហើយ។

កៈ  ហ្នឹងហើយប៉ុន្តែដំបូងឡើយដូចជាអ៊ំមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ទាំងស្លាប់ទាំងរស់ចឹងហាំ??

ខៈ តែម៉ែមួយឪមួយទេអី?

កៈ ចាំ!!!

ខៈ ញ៉ុមមានឪ២ហ្នួ!!!

កៈ ជាមួយម៉ែឪបង្កើតហា?

ខៈ ឪបង្កើតមានតែ២នាក់ទេ ឥឡូវបងញ៉ុមស្លាប់បាត់ហើយនៅតែញ៉ុមមួយ។

កៈ ចាំ!!

ខៈ ហើយ នឹងម៉ែ ឪស្លាប់បាត់ហើយ។

កៈ ហ្នឹងហើយចឹងតើអ៊ំជាកូនពៅឬក៏កូនបង?

ខៈ ញ៉ុមទី២ ទី១ស្លាប់។

កៈ ទី១ស្លាប់ !!ចឹងបងប្អូនសរុបទាំងអស់?

ខៈ បងប្អូនដែលនៅសព្វថ្ងៃនេះមានតែខ្ញុំម្នាក់ទេ។

កៈ ចាំ!!

ខៈ ដែលបងប្អូនខាងឪញ៉ុមបង្កើតនេះណាស់មានតែញ៉ុម២នាក់ហើយបងញ៉ុមស្លាប់មួយហើយនៅញ៉ុមមួយហើយនឹងម៉ែមួយទេ។

កៈ ចឹងបងប្អូនតែ២នាក់ទេចឹង??

ខៈ ចាំ!!

កៈ ហ្នឹងហើយចឹងអ៊ំជាកូនទី២គឺជាកូនពៅ ដូចជាពោះតែមួយចឹងហាំ!!!តើបងអ៊ំគាត់ឈ្មោះអីគេដែរ?

ខៈ ស្រុកហេ?

កៈ ឈ្មោះរបស់បងអ៊ំហាំ?

ខៈ គាត់ឈ្មោះប៊ី ចាន់ផល ប៉ុន្តែគាត់ស្លាប់បាត់ហើយហ្នឹងហា៎!!

កៈ ចា៎!!គាត់ស្លាប់មូលហេតុអីដែរអ៊ំ?

ខៈ គាត់ឈឺ គាត់ឈឺអារបៀបដូចសរសៃប្រាសាទ អារបៀបដូចធ្វើទុកក្បាលអីចឹងហា៎!!

កៈ នៅជំនាន់ណាដែរអ៊ំ?

ខៈ គាត់ទឹមតែស្លាប់ឥលូវៗហ្នឹងទេប្រហែលទឹមបាន១ឆ្នាំទេ។

កៈ ហ្វ៎!

!ខៈ ឥឡូវៗនេះឯង។

កៈ ចា៎អានិតគាត់ហា៎ចឹង!!!ចឹងអ៊ំមានអនុស្សាវរីយ៍អីខ្លះជាមួយបងប្រុសរបស់អ៊ំហា?គាត់ជាមនុស្សម៉េចដែរចឹង?

ខៈ អត់មានអនុស្សាវរីយ៍អីផង មិនដែលមានឃើញសប្បាយចិត្តអីផង!!

កៈ ធ្លាប់លេងជាមួយគ្នាអីចឹងហា៎!!!

ខៈ នៅបែកគ្នារហូតអត់ដែលនៅជុំគ្នាទេ។

កៈ ម៉េចចឹង?

ខៈ បានប្តីហើយគេនៅប្តីគេញ៉ុមនៅប្តីញ៉ុមឯណោះ។

កៈ ចុះពេលនៅពីតូចមកនៅជាមួយម៉ែឪឥវ៉ាន់ចឹង មានអីគេលេងជាមួយគាត់ខ្លះ ?

ខៈ អត់មានអីញ៉ុមនៅជាមួយគេហ្នឹង បែកពីម៉ែ នៅជាមួយគេ ដំចឹងទៅញ៉ុមវាយ៉ាប់ណាស់!!! យើងមិនសូវបាននៅជិតម៉ែទេ!!

កៈ ចា៎!!

ខៈ បែកពីគាត់តូច!!

កៈ ហេតុអីបានជាអ៊ំត្រូវបែកពីគាត់ទូច បែកពីម៉ែវិញថី?

ខៈហ៊ីម៉ែញ៉ុមគាត់ថាលេខញ៉ុមឆុងម៉េចទេអត់អោយនៅជិតអោយញ៉ុមនៅជាមួយគេវិញ។

កៈ ចឹងបើវាឆុងគ្នាចឹងវាព្រាត់ប្រាស់គ្នាអ៊ំហេ?

ខ៖ ចាំ!!

ក៖ តែឆុងចឹងវាព្រាត់ប្រាសគ្នាហើយ ហើ យនឹងមែនទេអ៊ំ?

ខ៖ តែញុំមអោយតែសព្វថ្ងៃនេះអោយតែថាឃើញគាត់ឈឺញ៉ុមទៅជិតគាត់ញ៉ុមឈឺដែរ ចឹងញ៉ុមអត់ហ៊ានទៅជិត។

ក៖ ហ្នុំចឹងទៀត !!

ខ៖ ថ្ងៃមុនឈឺបិសងាប់បិសរស់ ញុំមចង់ទៅមើលម៉ែញុំមណាស់!!!ទៅលេងគាត់ស្រាប់តែញ៉ុមឈឺដែរ ដល់ចឹងញុំមអត់ហ៊ានទៅទេ ញុំមអោយប្តីញុំមទៅកំដរគាត់។

ក៖ ចាំ!!

ខ៖ បានត្រឹមតែដឹ ងថាម៉ែឈឺទេ អត់បានទៅជិតថៃគាត់ទេណាស់!!អោយប្តីទៅថៃជំនួសហ្នឹងហើយបានថាញ៉ុម ឆុងគ្នា។

ក៖ ឃើញមុខគ្នាដឹងតែឈឺម៉ង?

ខ៖ ចាំ!!ហ្នឹងហើយមិនជឿសួរកូនញ៉ុមហ្នុំ!!!ទៅថ្ងៃមុនថាមកធ្វើអីទេ តែមកឈឺ !!ញ៉ុមនឹកម៉ែពេក ។ ម៉ែនៅភ្នំពេញហ្នុំម៉ែនៅឆ្ងាយនៅជាមួយបងនោះណាស់!!

ក៖ ចាំ!!

ខ៖ ឥឡូវបងស្លាប់បាត់ទៅ នៅជាមួយគេជិតនោះទៅ នៅជាមួយមីងមាអីចឹងទៅណាស់!!

ក៖ ចាំ!!

ខ៖ នៅជាមួយគេនឹងទៅ ញុំមវាក្រមកមិនកើតទេ។

ក៖ ចាំ!!

ខ៖ ញុំមអត់អីអោយគាត់ហូបក្រពេករកបាយមិនបានហូបទេហើយចឹងហូបអង្ករគីឡូថ្ងៃណាបានថ្ងៃណាអត់។

ក៖ ចាំ!!

ខ៖ ថាញុំមវេទនាមែនទែនញ៉ុមកំសត់ ណាស់តស៊ូទំរាំបានប៉ុណ្ណេះ។

ក៖ ហ្នឹងហើយ។

ខ៖ ចង់ងាប់ចង់រស់ហើយ។

ក៖ ចឹងបងប្រុសអ៊ំទឹមតែស្លាប់ពេលឆ្នាំទៅមិញហ្នឹងទេហោ?

ខ៖ បងញ៉ុមទឹមស្លាប់ឆ្នាំទៅនេះឯង?

ក៖ ហើយគាត់អ្នកធ្វើការអីដែរអ៊ំ?

ខ៖ គាត់អ្នកលក់ដូរនៅផ្ទះ។

ក៖ ហ្អ៎!!

ខ៖ មុខរបរគាត់លក់កាហ្វេ កាហ្វេហើយញ៉ុមអត់ចេះរកស៊ីអី ទេ អត់ចេះអក្សរផងហ្នឹង បើញ៉ុមមិនដែលបាននៅជុំម៉ែមិនដែលបាននៅរៀន នៅជាមួយគេ។

ក៖ ហើយគាត់មានដែលបានផ្តល់លុយអីអោយអ៊ំទេ?

ខ៖ ឥឡូវនេះគាត់ចាស់ហើយញ៉ុមក៏លែងយកដែរ គាត់ចាស់ហើយ ញ៉ុមអត់មានអីផ្ញើរគាត់វិញផង។

ក៖ ចា៎!!

ខ៖ ញ៉ុមឃើញខ្ជិលគាត់ចាស់!!!

ក៖ ចា៎!!

ខ៖ ដែលមានលុយអីអោយគាត់។

ក៖ ចឹងអ៊ំសំរាប់ម្តាយរបស់អ៊ំគាត់ឈ្មោះអីគេដែរទាំងត្រកូលរបស់គាត់ហា៎?

ខ៖ ប៉ោរ ទិព្វ។

ក៖ ប៉ោរ ទិព្វ?

ខ៖ ចា៎!!

ក៖ ចា៎!!ចុះឪពុកអ៊ំឈ្មោះអីវិញ?

ខ៖ ប៊ី ឆៃល។

ក៖ ប៊ី ឆៃល !!ជនជាតិគេឬក៏ខ្មែរ?

ខ៖ ខ្មែរ គាត់កាត់ចិន។

ក៖ ហ្ហ៎!!

ខ៖ គាត់កូនកាត់ចិនហា៎!!!

ក៖ ចា៎ហើយចឹងឈ្មោះបឺ ឆៃល ហ្ហ៎ឈ្មោះឡូយ។

ខ៖ បឺ ឆៃល ដល់កូនមកបឺចាន់មុំ បឺចាន់ផល។

ក៖ បឺឆៃល ។

ខ៖ ហ្នឹងហើយយកត្រកូលតាមប៉ាញ៉ុម។

ក៖ ចឹងអ៊ំគាត់ទាំង២គាត់មានអាយុប៉ុន្មានហើយម្ដាយអ៊ំគាត់អាយុប៉ុន្មាន ៨០ប៉ុន្មាន?

ខ៖ ប៉ាញ៉ុមគាត់ប្រហែល៩០ហើយបានគាត់ស្លាប់។

ក៖ ចា៎ចុះម្ដាយឥលូវ?

ខ៖ ម្ដាយហេ?

ក៖ ចា៎!!

ខ៖ ម្ដាយ៨០ជាង។

ក៖ ៨០ជាងហ្នឹងហើយ!!តែឥឡូវឪពុកអ៊ំស្លាប់បាត់ហើយ?

ខ៖ ប៉ាស្លាប់បាត់ហើយតែម៉ាក់នៅ!!!

ក៖ ចា៎!!

ខ៖ នៅសព្វថ្ងៃ។

ក៖ គាត់ស្លាប់ដោយសារជរាឬក៏ម៉េច?

ខ៖ គាត់ចាស់ហើយ ចាស់ជរាហើយប៉ា។

ក៖ ហ្ហចឹងបានគាត់ស្លាប់ហ្នឹងហ្ហ៎!!!ហ្នឹងហើយ។

ខ៖ ចាស់ជរាហើយ។

កៈ ចាំ!!ចឹងអ៊ំតើម្ដាយអ៊ំគាត់កើតឆ្នាំអីគេដែរខ្មែរ?

ខៈ អត់សូវចាំដែរហ្នឹងហាំ!!!

កៈ ចាំតែគ្រាន់តែថាឥឡូវអាយុគាត់៨០ជាងហើយ??

ខៈ  ញ៉ុមដឹងថាគាត់ចូលអាយុ៨០ជាងហើយតែអត់ដឹងញ៉ុមអត់សូវចាំឆ្នាំកំណើតរបស់គាត់ទេណាស់!!!

កៈ ចាំ!!

ខៈ ព្រោះអីញ៉ុមអត់សូវបានញែសញោះជាមួយគាត់ ខ្លាចម៉ែមិនហ៊ាននិយាយ ច្រើនជាមួយ។

កៈ ចាំ!!ចុះសំរាប់ប៉ាអ៊ំចាំអីគេខ្លះ?

ខៈ ប៉ាក៏ចឹងដែរ អត់ហ៊ានជាមួយម៉ង តែខែឆ្នាំរបស់គាត់ក៏ញ៉ុមអត់ហ៊ានសួរដែរដឹងតែដឹងតាមអាយុមីងមាប្រាប់ទៅ៩០ ៩០ទៅ។កៈ ចាំ!!ខៈ ម៉ែញ៉ុមតែ៨០ ៨០ជាងហើយដឹងតែ៨០ជាង។ព្រោះមែនថាញ៉ុមចិត្តអាក្រក់រឿងឆ្នាំកំនើតគាត់ទេហាំព្រោះអីគេស្លាប់បាត់ហើយ  តែញ៉ុមអត់ចាំ!!!

កៈ ហ្នឹងហើយចឹងអ៊ំសំរាប់ស្រុកកំណើតរបស់ម៉ាក់សំរាប់ម្ដាយរបស់អ៊ំគាត់នៅឯណាដែរ?

ខៈ នៅខេត្តតាកែវ។

កៈ នៅកន្លែងអ៊ំកើតហ្នឹងដែរ?

ខៈ ចាំ!!

កៈ ចុះឪពុក?

ខៈ ឪពុកក៏នៅហ្នឹងដែរ។

កៈ អ្នកតាកែវដូចគ្នា?

ខៈ ចាំ!!

កៈ នៅត្រាំកក់ហ្នឹងហោ?

ខៈ ចាំ!!

ក៖ សុទ្ធតែអ្នកស្រុកត្រាំកក់ហ្នឹង!!!

គេហៅភូមិឃុំអីគេដែរនៅហ្នឹង?

ខ៖ ភូមិហ្នឹងគេហៅ ទេញុំមដឹងតែគេហៅឃុំចារ ស្រុកព្រៃកប្បាស ខេត្តតាកែវ។

ក៖ ចាំហ្នឹងហើយ។ចឹងអ៊ំតើពេលឪពុកអ៊ំនៅរស់គាត់ធ្វើការអីសំរាប់ចិញ្ចឹមជីវិតទាំងគ្រួសារអីដែរ?

ខ៖ កាលហ្នឹងគាត់ជួញដូរអីតិចតួចដូចអារបៀបលក់ស្អីគាត់ លក់គ្រឿងស្អី គ្រឿងស្អីគេទេញុំមមិនសូវបានទៅជិតគាត់ទេ។

ក៖ អត់ដឹងដែរចុះម្ដាយរបស់អ៊ំ?

ខ៖ ម៉ែញុំមរាល់ថ្ងៃពីមុនពីដើមមកគាត់លក់គុយទាវហើយកាហ្វេហើយបងញុំមគេចេះតំរិះតាម គាត់ហ្នឹងហាំ!!!

ក៖ ចាំ!!

ខ៖ តែញុំម ញុំមអត់លួង់សុទ្ធហើយអត់ចេះអីទេដូចញុំមថាអញ្ចឹងនៅជា មួយគេ!!

ក៖ ហ្នឹងហើយ។

ខ៖ នៅជាមួយគេមិនបានរៀនមិនបានសូត្រទេលួង់អត់ចេះអក្សរអីទេ!!!

ក៖ ចាំ!!!ចឹងអ៊ំតើឪពុកអ៊ំគាត់ជាមនុស្សបែបម៉េចដែរ?

ខ៖ ប៉ាញុំមហ្ហ៎?ក៖ ចាំ!!ខ៖ ប៉ាញុំមអារបៀបដូចថាគាត់រកស៊ីអីដែរដូចថាប៉ះកង់អីជាងម៉ូតូអីប៉ះចឹងទៅណាស់!!

ក៖ ចាំហើយគាត់ចរិកបែបណាដែរអ៊ំ?

ខ៖ ចរិកគាត់!!

ក៖ ម៉េចទៅអ៊ំ?

ខ៖ ព្រោះញុំមបែបពីគាត់ដែរហ្នឹងហាំញុំមអត់បាននៅជិតគាត់ទេ នៅបែកគេ។

ក៖ ម្ដាយក៏អត់ដឹងដែរចឹង?

ខ៖ ចា៎!!!

ក៖ ហ្នឹងហើយ។

ខ៖ ញ៉ុមបែកពីគាត់ គ្រាន់តែបានប្ដីហើយញ៉ុមលែងនៅជិត។

ក៖ ចុះពេលអ៊ំនៅពីក្មេងហ្នឹងតើអនុស្សាវរីយ៍របស់អ៊ំជាមួយឪពុកម្ដាយម៉េចដែរ?

ខ៖ និយាយទៅគ្មានភាពសប្បាយអីទេ វេទនារហូត។

ក៖ វេទនារបៀបម៉េចទៅអ៊ំ?

ខ៖ ដូចថានឹកឃើញម៉ែឪដូចថាកើតមកហើយយើងវាមិនបាននៅជួបជុំចឹងហា៎!! តូចចិត្តដូចថាយើងមានម៉ែនឹងគេដែរនៅជាមួយវាមិនកើត។

ក៖ ចា៎!!!

ខ៖ ហើយថាបើឯងនៅជិតអញឯងឆុងអញងាកឈើហើយចឹងញ៉ុមក៏នៅជាមួយគេរកស៊ីជាមួយគេជួយមើលកូនអោយគេចិញ្ចឹមសត្វអីបន្តិចបន្តួចចឹងហា៎!!

ក៖ ចា៎!!

ខ៖ ជាមួយគេចឹងទៅដូចញ៉ុមរាល់ថ្ងៃញ៉ុមវេទនាចង់ងាប់ហ្នឹង ធ្លាក់ខ្លួ នវេទនាឈឺផងអីផង។

ក៖ ចុះពេលមុនមកជីវភាពម៉េចដែរចឹង?

ខ៖ ពីមុនហេ៎?ពីមុនដូចវាមិនដាបដល់ថ្នាក់នេះម៉ាល្មមម៉ាហូបចុកបានហា៎!!!ឥឡូវយ៉ាប់ យ៉ាប់អត់ដូចមុន ចង់យ៉ាប់ដោយសារតានោះវាចាស់កូនវារកដែររកម្នាក់ឯងរកវាមិនឈ្នះទប់វាមិនឈ្នះទេ។

ក៖ ចា៎!!

ខ៖ បាយអង្ករហូបអីមិនគ្រប់គ្រាន់ អាមួយនេះគ្នាវាដូចថាវាពិការចុះនៅតែផ្ទះអត់ធ្វើអីគេកើតទេ។

ក៖ គាត់ចឺបានចឹងវិញអ៊ំ?

ខ៖ អារបៀបប្រពន្ធវាលែងទៅវាបែកចិត្ត ចិត្តចង់ឆ្កួតចង់អីចឹងទៅណាស់!!យ៉ាប់អ៊ំរាល់ថ្ងៃកូន៣ ដែរប៉ុន្តែដូចវេទនាណាស់ មីនោះមេម៉ាយអានេះគ្នារកស៊ីដែរប៉ុន្តែវាអត់ទាន់មាត់តានោះគាត់ចា ស់ រត់ម៉ូតូឌុបនោះម៉ូតូបាក់បែក តិចជាង ម៉ូតូចាស់វាឧស្សាហ៍ខូចហ្នំ!!!អត់រកអីហូបទេ។

ក៖ ចាំហ្នឹងហើយ។

ខ៖ ព្រឹកមិញអត់មានបានអីហូបទេ នាំគ្នាហូបជាមួយទឹកត្រីទឹកអីចឹងទៅចេះតែទ្រាំទៅ!!!

ក៖
ហ្នឹងហើយ។ចឹងអ៊ំសំរាប់ជីដូនជីតារបស់អ៊ំវិញម្តងខាងម្តាយអ៊ំចាំថាគាត់ឈ្មោះតាអីយាយអីដែរអត់?

ខ៖ យាយញ៉ុមហ្នំ?

ក៖ ចាំ!!

ខ៖ យាយញ៉ុម ញ៉ុមកើតអត់ទាន់ផង។

ក៖ កើតអត់ទាន់គាត់ទេ?ចឹងដឹងថាគាត់កើតនៅក្នុងជំនាន់ណាដែរអត់អ៊ំ?

ខ៖ ម៉ែញ៉ុមហ្នំ?

ក៖ យាយអ៊ំខាងម្តាយ។

ខ៖ យាយហេ៎?

ក៖ ចាំ!!

ខ៖ ថាគាត់អត់ដែលនិយាយអីទេ!!

ក៖ បិទជិតឆឹងម៉ងអ៊ំហេ៎?

ខ៖ ចាំ!!នេះញ៉ុមបានតែរូបថតតាំងគាត់ហ្នឹងឯង!!

ក៖ ចាំ!!

ខ៖ តែញ៉ុមអត់ដឹងពីប្រវត្តិគាត់ អត់មាន ដឹងប្រវត្តិអីទេ ដឹងតែពីតាំងគាត់តែប៉ុណ្ណោះ ម៉ែក្មេក ម៉ែក្មេកបើគាត់នៅប្រហែលជាគាត់អាចស្តា ល់ពីប្រវត្តិគាត់ញ៉ុមអត់!!!

ក៖ អត់ស្គាល់ទេ?

ខ៖ ចាំ!!

ក៖ ចុះខាងឪពុករបស់អ៊ំស្គាល់ឈ្មោះថាតាអីយាយអីទេ?

ខ៖ ហ្នំអាហ្នឹងរឹតតែឆ្ងាយទៀត។

ក៖ ចុះប៉ាម៉ាក់មានដែលប្រាប់អំពីគាត់ឈ្មោះអីទេ?

ខ៖ អត់ដែលនិយាយអីសោះ មិនដែលនិយាយអីទេព្រោះអត់សូវបាននៅជិះគាត់ទេ។

ក៖ ហ្នំ!!

ខ៖ ចាំដូចញ៉ុមនិយាយចឹង ឃ្លានពីគាត់ឆ្ងាយញ៉ុមនៅជាមួយគេដូចញ៉ុមនិយាយប្រាប់មិញចឹងហាំ!!!

ក៖ ហ្នឹងហើយ។

ខ៖ មិនបាននៅជិតគាត់ទេគ្រាន់តែថាមើលទៅពេញវ័យឡើងទៅនៅជាមួយគេហើយ ពេលហ្នឹងអាយុប្រហែលកើតហើយចេះដឹងបន្តិចបន្តួចចឹងហាំ!!!អោយទៅនៅជាមួយគេ នៅជាមួយគាត់ឈឺ។

ក៖ ចឹងទៀត។

ខ៖ ឧស្សាហ៍ឈឺឆុងលេខគាត់។

ក៖ ចាំ!!

ខ៖ ហើយញ៉ុមថាតូចចិត្តដូចថាកើតមកហើយមិនបានជួបជុំម៉ែឪឯងនៅបែកគាត់រហូតដល់ឪស្លាប់ ម៉ែញ៉ុមនៅដល់សព្វថ្ងៃអត់ហ៊ានទៅជិត។

ក៖ គាត់នៅជាមួយអ្នកណាគេវិញ?

ខ៖ នៅជាមួយអី នៅជាមួយអីមួយទៀត។ក៖ ចាំ!!ខ៖ ហើយញ៉ុមតេទៅគាត់ម្តងៗគាត់យំគាត់យំនឹកកូនដែរប៉ុន្តែកូនទៅម៉េចកើតអត់មានលុយអត់មានកាក់អី។

ក៖ ចឹងទៀត ចឹងអ៊ំសំរាប់សំណួរបន្ទាប់ទៀតតើក្រុមគ្រួសាររបស់អ៊ំក្នុងខេត្តហ្នឹងយូរនៅអ៊ំ រយៈពេលប៉ុន្មានឆ្នាំហើយ?

ខ៖ ញ៉ុមនៅហ្នឹងយូរហើយតាំងពីម៉្ញុំនេះអត់ទាន់មានផ្ទះទេសុទ្ធតែព្រៃ ស្ងាត់តែផ្ទះញ៉ុម តែផ្ទះញ៉ុមមួយដំបូងហាំ!!!

ក៖ ចាំ!!

ខ៖ មានតែផ្ទះញ៉ុមមួយហើយមិនមែនប៉ុណ្ណឹងទេ តូចជាងនេះដូចខ្ទមទ្រុងមាន់ចឹងហើយញ៉ុមវេទនាហើយញ៉ុមចេះតែមកនៅឈឺទៅ លក់ផ្ទះលក់អីអស់មួយសារហើយដល់ពេលញ៉ុមមកនៅអញ្ចឹងមកទិញគេចឹងហិ!!!ហើយអញ្ចេកអត់ទាន់មានផ្ទះមានដីអត់ទាន់ស្រលះចឹងទេ!!! មានតែញ៉ុមតែឯងស្ងាត់ជ្រាប មានតែផ្លូវនេះគេឧស្សាហ៍ប្លន់ណាស់!!

ក៖ ហ្ហ៎!!

ខ៖ ផ្លូវនេះស្ងាត់ណាស់!!!

ក៖ ចាំ!!

ខ៖ ហើយញ៉ុមចេះតែនៅទៅញ៉ុមវាក្រ ញ៉ុមអត់មានអីអោយវាប្លន់ទេចេះតែនៅទៅណាស់!!តស៊ូរហូតដល់បានសព្វថ្ងៃនេះ។

ក៖ ចាំ!!

ខ៖ បានដល់សព្វថ្ងៃ នេះយ៉ាប់វាមានអ្នកធ្វើបាបញ៉ុមទៀត!!ធ្វើបាបអញ្ចេះអញ្ចុះលក់ដូរអីមិនបានលក់បានបន្តិច បន្តួចកាច់កង់គ្នា ពិបាកណាស់ថាសុំត្រឹមតែមួយហូបហូបវាមិនចង់អោយយើងហូបទៀតរាល់ ថ្ងៃហាំ!!

ក៖ ចាំ!!

ខ៖ សត្រូវយើងជិតខាងវាយ៉ាប់ យើងឃើញយើងវាក្រគេមើលងាយចឹងហាំ!!តែញ៉ុមអត់រវីរវល់ជាមួយគេទេ ញ៉ុមប្រាប់កូនញ៉ុមថាខំប្រឹងរកហូបទៅ អ្នកណាធ្វើអីក៏ធ្វើទៅយើងដឹងតែពីរកហូប ក្រពះយើងឆ្អែតៗញ៉ុមអត់មានអីទេញ៉ុមអត់មានរករឿងអ្នកណាគេទេ!! ទំនាស់ជាមួយអ្នកណាមានតែគេរករឿងញ៉ុមវិញ ហើយមិនជឿងសួរអ្នកជិះខាងមើល ស្លូតអត់មានចេះទៅណាទៅណីឃើញទេអស់ពីផ្ទះទៅដី អត់ពីដីទៅផ្ទះមើលកូនចៅលក់ដូរបន្តិចបន្តួចកំប៉ែកកំប៉ុកតែប៉ុណ្ណឹងឯងអត់មានដែលដើរផ្ទះគេទេ។

ក៖ ចាំ!!

ខ៖ នៅតែផ្ទះតារត់ឌុបយប់ឡើង ចូលផ្ទះ។

កៈ ចឹងអ៊ំមានបងប្អូនសាច់ញាតិណាខាងជីដូនមួយអីណាមានរស់នៅប្រទេសក្រៅអីអត់?

ខៈ បងប្អូន បងប្អូនវាមានហើយតែវាគ្មានដាច់រយៈយូរហើយ។

កៈ ហើយគាត់ទៅនៅឯណាវិញទៅ?

ខៈ ឃើញតែទៅនៅស្រុកគេហ្នឹងតែមិនដែលផ្ញើរលុយផ្ញើរកាក់អីបាត់ស្រមោលឈឹង។

កៈ ប្រទេសណាវិញ ដូចជាអាមេរិចចឹងហា ឬក៏ថៃឬក៏វៀតណាមមានអ្នកណាគេទៅក្រៅទេ?

ខៈ បើសិននៅក្រៅក៏គ្មានន័យអីដែរ មិនដែលមានលុយផ្ញើរអីអោយប្អូន១០០លុយខ្មែរអីអត់ផងបាត់ស្រមោលឈឹង។

កៈ ចាំ!!ហ្នឹងហើយ។

ខៈ ញ៉ុមរាល់ថ្ងៃមានដូចអត់មានចឹង!!ខ្ញុំមិនដែលបានស្គាល់ជាតិលុយគេចាយផង។

កៈ ចាំ!!

ខៈ មិនដែលមានទេ។

កៈ ចាំចឹងអ៊ំសំរាប់អាពាហ៍ពិពាហ៍របស់អ៊ំវិញម្តង តើស្វាមីអ៊ំតើគាត់ឈ្មោះអីគេដែរ?

ខៈ ទូត វិចិត្រ។

កៈ ទូត វិចិត្រ !!ចឹងអ៊ំរៀបការជាមួយអ៊ំប្រុសនៅឆ្នាំណាដែរ?

ខៈ ៨៥(១៩៨៥)។

កៈ ១៩៨៥ ចាំហ្នឹងហើយ។អ៊ំចាំថានៅក្នុងខែណាទេចាំពេលដែលរៀបការ។

ខៈ ដឹងតែ៨៥(១៩៨៥)ខែ០៥។

កៈ ចាំ!!

ខៈ អត់ចាំថ្ងៃ។

កៈ អត់ចាំថ្ងៃទេ!!!ចឹងការរៀបការរបស់អ៊ំត្រូវបានរៀបចំឡើងដោយឪពុកម្តាយឬក៏អ៊ំស្រលាញ់គ្នាជាមួយស្វាមីដោយចិត្តឯង?

ខៈ ម៉ែរៀបចំអោយ។

កៈ ធ្លាប់ស្គាល់ប្តីពីមុនហោ?

ខៈ ពីដំបូងញ៉ុមមិនដែលស្គាល់ទេ តែដូចថាគាត់ធ្វើការខាងទាហ៊ានហ្នឹងណាស់!!គាត់ធ្វើការនៅក្បែរផ្ទះចឹងទៅគាត់ចេះតែហៅលេង លេងសើចៗរាប់អានធម្មតាទេតែដល់ពេលក្រោយមកគាត់ស្រលាញ់ក៏គាត់ចូលសួរអ៊ីញ៉ុមហ្នឹងហើយ ចឹងបានជាប់ដល់សព្វថ្ងៃនេះឯង!!

កៈ ក្តីស្នេហាចាប់ផ្តើមពីពេលហ្នឹងទៅ?

ខៈ ចាំបានរៀបចំទៅ។

កៈ មនុស្សម្នាក់ៗតែងតែមានមួយហ្នឹងហើយអំណោះ?

ខៈ ចាំ!!

កៈ កំរថាអ្នកណាគេអត់មួយហ្នឹង ណាស់!!

ខៈ មួយហ្នឹងឯង អត់មាន២ ៣ទេមានតែមួយហ្នឹងឯង។

កៈ ចឹងពេលអ៊ំប្រុសចូលស្តីដណ្តឹងអ៊ំគាត់អោយមានជំនូនអីហេំ?

ខៈ អោយ កាលហ្នឹងគាត់ទាហាន គាត់អោយមេបញ្ជាគាត់ចូលមកសួរ។

កៈ ហើយមានអោយជាថ្លៃទឹកដោះអីអត់?

ខៈ អោយដែរ។

កៈ អោយប៉ុន្មានដែរអ៊ំ?

ខៈ កាលហ្នឹងអោយប៉ុន្មានទេលុយខ្មែរយើង ចាយលុយប៉ុន្មាន១កាក់ ២កាក់ មិនដឹងបានប៉ុន្មាន ម៉ែញ៉ុមអ្នកយក។

កៈ អ៊ំអត់ដឹងម៉ងហោ?

ខៈ ចាំ!!

កៈ ចុះមានអោយជាមាសជាផ្ទះជាដីអីអត់?

ខៈ អត់ទេអោយជាលុយ។

កៈ 	អោយជាលុយៗចឹងអ៊ំអាចប្រាប់ញុំាមពេលដំបូងដែលអ៊ំហើយនឹងស្វាមីបានជួបគ្នាហាំ? ជួបគ្នាលើកដំបូងនៅឯណាវិញ?

ខៈ ជួបគ្នាលើកដំបូងហោ?

កៈ ចាំ!!

ខៈ ញុំាមនៅសៀមរាប។

កៈ ចាំ!!

ខៈ ដល់ពេលការហ្នឹងម៉ែញុំាមម កយកទៅការនៅភ្នំពេញវិញ។

កៈ ចឹងទៀត។

ខៈ ព្រោះញុំាមនៅជាមួយគេហ្នំ!!ដល់ពេលចឹង ដល់ពេលការគាត់យកទៅការខ្លួនគាត់មីងគាត់គេថាការអោយតែម៉ែថាមិនបាច់ទេ អញយកទៅការខ្លួនឯង។

កៈ ម៉ែរបស់អ៊ំហ្នឹង?

ខៈ ចាំ!! ម៉ែញុំាមថាចឹងហាំ!!

កៈ ចឹងពេលទៅជួបគ្នាហ្នឹងអត់ឆុងទេហោ?

ខៈ អត់ឆុងទេ អាហ្នឹងថាយើងអត់បាននៅជិតគាត់យូរ រៀបចំហើយយើងរៀបចំចេញមកវិញទៀត អត់បានយូរទេ។

កៈ នៅជាមួយគ្នាយូរឆុងគ្នាម៉ង?

ខៈ ចាំបើថាអោយតែឃើញញុំាមទៅ យ៉ាងយូរ៤ ៥ថ្ងៃហ៊ុអញឈឺទៀតហើយ!!ដល់ចឹងញុំាមនៅមិនបានយូរទេ ញុំាមទៅវិញហើយ។

កៈ ចឹងទៀត !!ចឹងអ៊ំសំរាប់ការរៀនភាសារបស់អ៊ំវិញ អ៊ំមានដែលធ្លាប់រៀនភាសាអីក្រៅពីភាសាខ្មែរទេ។

ខៈ អត់ចេះ អត់ចេះអក្សរអីផង។

កៈ អត់ចេះទេហោ??

ខៈ ថាញុំាមអត់ចេះទេ។

កៈ ហើយអ៊ំរៀនបានថ្នាក់ទីប៉ុន្មានដែរ?មានបានចូលសាលាអត់?

ខៈ អើយតិចតួចទេ តែអានមិនចេះអានទេ បានត្រឹមតែទី៣ ទី៤ ថាអត់សូវចេះទេ អត់សូវចាំទេ

កៈ ហើយពេលហ្នឹងចឹបានឈប់រៀនចឹង?

ខៈ ថាពេលហ្នឹងញ៉ុមវេទនានៅជាមួយគេ។កៈ ហ្ហ៎!!ខៈ វាមិនបានរៀនជិតដល់ទេ!!

កៈ ចា៎!!

ខៈ ទំរាំ បានរៀន រៀនបានអក្ខរកម្មយប់ ពេលហ្នឹងវាមិនបានរៀនថ្ងៃទេ មិនមែនរៀនដូចគេជាសិស្ស សាលាពេញទេ អក្ខរកម្មយប់ រៀនមួយភ្លែតៗ មិនមែនរៀនបានដូចគេណាស់!!!

កៈ អ៊ំមានចាំអក្សរទល់សព្វថ្ងៃទេ?

ខៈ ចា៎?

កៈ ចាំអក្សរអានហា៎??

ខៈ និយាយទៅវាមិនសូវចេងចាំទេ!ភ្លេចមុខភ្លេចក្រោយអត់សូវចេងចាំទេភាំងលិចភាំងកើតចឹង ហា៎!!វាថាមានអ្នកណាសួរចឹងទៅ ដល់ថ្ងៃសួរទៅភ្លេចទៀត ភ្លេច ចុះឯង។

កៈ ចា៎ហ្នឹងហើយចឹងអ៊ំពេលរៀនហ្នឹង អត់រៀននៅសាលាណាអី?

ខៈ អត់រៀននៅសាលាទេ រៀនដូចថាសាលាគេ រៀននៅវត្តម៉ង!!

កៈ រៀននៅហ្នឹងវត្ត?

ខៈ វត្ត។

កៈ ចឹងអ៊ំមានការចេងចាំអីគេខ្លះពីការសិក្សារបស់អ៊ំថាអ្នកណាដែលគេបង្រៀនរឺម៉េចដែរ?

ខៈ គ្រូអាចាងហ្វាងគេជ្រើសរើសណែអ្នករៀនអក្ខរកម្ម គេអោយមករៀនអក្ខរកម្ម។

កៈ ចា៎!!

ខៈ គេ ជ្រើសរើសគ្រូថ្នាក់ទី៣ ទី៤ ទៅញ៉ុមរៀនបានគ្រូ៣ហ្នឹង ទី៣ ទី៤ទៅ ប្តីញ៉ុមមកទៅញ៉ុមឈប់ ទៅការទៅ ហើយថាចង់រៀនតទៀតតែការប្តីហើយហ្នឹង ម៉ែថាការហើយឈប់រៀនឈប់អីទៅ ឈប់តាំងពីថ្ងៃហ្នឹងមកតាំងពីមានប្តី អត់ចេះអី។

កៈ ចឹងអ៊ំពេលហ្នឹងអត់មានមិត្តភក្តិ ស្និតស្នាលធំធាត់ជាមួយគ្នាទេពេលរៀនពេលនៅពីតូចមក ហាំ?

ខៈ មិត្តភក្តិវាបាក់បែកអស់ហើយ។

កៈ ហ្នឹងហើយគាត់ឈ្មោះអីគេដែរ?

ខៈ គេនៅជំដែកហ្នំ ប៉ុនព្រាត់គ្នាយូរហើយមិនដែលជួបគ្នាទេ។

កៈ ប៉ុន្តែគាត់ឈ្មោះអីគេវិញ?

ខៈ ឈ្មោះវាមិនពិរោះទេ ឈ្មោះមីនោះឈ្មោះការូច។

កៈ ការូច?

ខៈ ចាំ!!

កៈ ហ៊ីពិរោះសោះហ្នឹងហាំ!!

ខៈ ឈ្មោះវាយ៉ាប់ដែលហ្នឹងហាំ!! វាជាអ្នកកំព្រាម៉ែដែរហ្នឹង។

កៈ ហ្នំស្និត។

ខៈ ហ្នឹងហើយស្និតស្នាលជាមួយគ្នាតាំងពីនៅក្រមុំហ្នំ!!តែ២នាក់ហ្នឹង។

កៈ ដើរទៅណាជាមួយគ្នាចឹងទៅ?

ខៈ ចាំដើរជាមួយគ្នាចឹងទៅ ដល់ពេលឥលូវបែកគ្នាយូរហើយគ្រាន់តែខ្ញុំការប្តីមកវាក៏បែកខ្ញុំ។

កៈ ចាំ!!អ៊ំធ្លាប់ធ្វើការស្រែចំការទេ?

ខៈ អត់ដែលផង គ្មាន។

កៈ អត់មានស្រែធ្វើទេតាំងពីតូចមក?ខៈ អត់។កៈ ចឹងធ្វើអីគេទៅ?

ខៈ កិច្ចការផ្ទះយើងតែប៉ុណ្ណឹងឯង អត់មានទៅធ្វើស្រែធ្វើស្រូវអីនឹងគេទេ គ្មានដែលចេះអីទេ។

កៈ ចាំចឹងសំរាប់ជីវិតរបស់អ៊ំការងារអីគេដែលអ៊ំឆ្លងកាត់ធ្លាប់ធ្វើចឹង?

ខៈ ឆ្លងកាត់ធ្វើដូចជាកិច្ចការផ្ទះ កាប់អុសកាប់អីយកមកដាក់ផ្ទះ អត់មានធ្វើអីធំដុំ ទៅឆ្ងាយៗអីអត់ហ៊ាន។

កៈ ចុះរាល់ថ្ងៃអ៊ំប្រកបមុខរបរលក់ដូរអីវិញ?

ខៈ កូនញ៉ុមវាលក់។

កៈ មិនមែនអ៊ំទេចឹង?

ខៈ អត់ទេ។

កៈ អ៊ំមានដែលលក់បន្លែលក់ត្រីអីអត់ចុះ?

ខៈ អត់ដែលផង។

កៈ នៅផ្ទះម៉ងហោ?ខៈ ចាំ!!កៈ ការហើយ។

ខៈ ព្រោះញ៉ុមវាខ្សោយវាមិនសូវ ដូចថាមិនសូវពេញកំលាំងអីទេ វារាងខ្សោយរាងឈឺ ដល់នេះឈឺទៀតហាំ!!អត់ស្រួលខ្លួនទៀតហាំ!!ខ្សោយក្រពះ ពោះវៀន ។

កៈ ចាំ!!

ខៈ ឧស្សាហ៍ឈឺហាំ!!

កៈ ចាំហ្នឹងហើយ ចឹងតើអើតាំងពីក្មេងរហូតដល់ពេលនេះជីវិតរបស់អ៊ំមានបានផ្លាស់ប្តូរអីគេខ្លះហើយដូចមានដែលបានធូរស្បើយឬក៏មានភាពសប្បាយរីករាយអីខ្លះអត់?

ខៈ មិនដែលទេ ពិបាកចិត្តដែរ។

កៈ អ៊ំសប្បាយចិត្តបំផុតនៅពេលណាវិញ?

ខៈ អត់ដែលមានសប្បាយអីផង មើលទៅវេទនា អត់មានសប្បាយ ពីដើមខ្វល់។

កៈ ចុះថ្ងៃការមានរំភើបអីទេអត់ចុះ?

ខៈ ហេអាថ្ងៃការហ្នឹងវាបានសប្បាយមួយភ្លែត វាមិនបានសប្បាយយូរ ។

កៈ ហ្នឹងហើយចុះដល់ពេលរៀបការជាមួយគ្នាជាមួយប្តីដែលមានអារម្មណ៍ថាសុភមង្គលអីអត់អ៊ំ?

ខៈ មានអារម្មណ៍ថាម៉េចទៅ ម៉ែអោយយកប្តីយកតាមគាត់។

កៈ ចាំ!!

ខ៖ អត់មានប្រកែក។

ក៖ អត់មានប្រកែកដឹងតែរស់នៅជាមួយប្ដី រស់អីហ្នឹងមក?

ខ៖ ចាំ!!

ក៖ ហ្នឹងហើយ។

ខ៖ គាត់អោយយក យកគាត់មិនអោយយកលើគាត់ ញ៉ុមអត់ហ៊ានដែរហ្នឹង គាត់អោយយក យក អត់ហ៊ានប្រកែកទេ។

ក៖ ចឹងទៀត?

ខ៖ ចាំម៉េចហ៊ានប្រកែកបើគាត់រកទុកដាក់អោយ។

ក៖ ចាំហ្នឹងហើយ ចឹងអ៊ំតើម្ហូបដែលអ៊ំចូលចិត្តពិសារម្ហូបអីដែរ?

ខ៖ ទន់ៗ ។

ក៖ ម្ហូបដែលជាចំណង់ចំណូលចិត្តអ៊ំតាំងពីក្មេងមកហាំ?

ខ៖ សាច់ត្រី។

ក៖ សាច់ត្រី !!ស្លរអីគេដែរ ?អាំងឬក៏ស្ងោរ?

ខ៖ ជួនកាលប្រហើរ ជួនកាលអាំងជួនកាលប្រឡាក់ចៀន។

ក៖ ចាំ!!

ខ៖ វាមិនបានហូបអីឆ្ងាញ់ៗ នឹងគេទេ សាច់ជ្រូកសាច់គោអីវាមិនសូវងាយទេ!! សាច់ត្រី!!

ក៖ ចាំ!!

ខ៖ យូរៗ។

ក៖ ហើយអ៊ំចេះធ្វើម្ហូបទាំងអស់ហ្នឹងអត់?

ខ៖ ញ៉ុមចេះ ចេះកិច្ចការម្ហូបខាងផ្ទះ។

ក៖ ចេះគ្រប់ម៉ងអ៊ំណោះ!!អ៊ំរៀនធ្វើម្ហូបពីអ្នកណាគេមកវិញ?

ខ៖ ចេះជាមួយពេលញ៉ុមនៅជាមួយគេហ្នឹង!!

កៈ ចាំគេបង្រៀន។

ខៈ នៅជាមួយគេ គេប្រាប់ ចេះសួរ ចេះដាំបាយចេះដាំបាយអីទៅ ចេះពីគេមកវិញ!!

កៈ ហ្នឹងហើយ។

ខៈ ចេះនៅជាមួយគេ។

កៈ ចាំចឹងអ៊ំតើចំរៀងណាដែលអ៊ំបានរៀនមកតាំងពីក្មេងហា?ដែលអ៊ំស្រលាញ់ជាងគេបទអីគេវិញ?

ខៈ ចូលចិត្តជាងគេភ្លេងការញ៉ុមហ្នំ!!

កៈ ភ្លេចការហេ?

ខៈ ចាំ!!

កៈ ស្រលាញ់ម៉ងហេ គេហៅបទអីគេដែរអ៊ំ?

ខៈ ភ្លេចដែរញ៉ុមចូលចិត្តជាងគេហេ?

កៈ ចាំ!!

ខៈ កាត់សក់កាត់អីហ្នឹងសប្បាយ ពេលម៉ែការអោ យ។

កៈ ចាំហើយនៅក្នុងគ្រួសារអ៊ំមានអ្នកណាដែលចេះលេងឧបករណ៍តន្រ្តីអីអត់?

ខៈ ទេដូចមិនដែលមានអ្នកណាគេទេ។

កៈ អត់មានទេ!

ខៈ អត់មានទេ។

កៈ ចឹងអ៊ំអាចប្រាប់ញ៉ុមនូវពេលជីវិតរបស់អ៊ំពិបាកបំផុតនៅក្នុងជីវិតហាំ តើពេលវេលាណាដែរ?

ខៈ តាំងពីញ៉ុមធ្លាក់ខ្លួនឈឺចាប់ផ្តើមពិបាករហូត រហូតដល់សព្វថ្ងៃពិបាកចិត្តរហូត មិនដែលមានសប្បាយចិត្ត ងាកណេះក៏អត់ងាកណោះក៏អត់ បាយក៏គ្មានអីក៏គ្មានញ៉ុមវេទនាណាស់ឆ្នាំនេះណោះ ដល់ចាប់ចូលចាស់មកដូចថាវាពិបាកម៉ងហាំវាមិនសប្បាយចិត្តទេ។

ក៖ ចាំ!!

ខ៖ មិនដែ លបានសប្បាយចិត្តទេ គិតតែពីគិតនោះ គិតតែពីគិតរហូតញ៉ុមមិនដែលបានសប្បាយទេ។

ក៖ ចាំអ៊ំដូចជាក្នុងជីវិតរបស់អ៊ំអ៊ំមានបទពិសោធន៍អីគេដែរល្អនៅក្នុងជីវិតដែរ?ការអត់ធ្មត់ ការតស៊ូព្យាយាមអីម៉េចដែរ?

ខ៖ ព្យាយាមអត់ហូប។

ក៖ ចាំ!!

ខ៖ ខំប្រឹងតស៊ូជាមួយប្តី នៅជាមួយប្តីវេទនាយ៉ាងណាក៏ចេះតែត ស៊ូដែរ។

ក៖ ចាំ!!

ខ៖ មានហូបអត់ហូបចេះតែតស៊ូជាមួយគាត់ទៅ ២នាក់ប្តីប្រពន្ធយើងទេ ចេះតែតស៊ូជាមួយគាត់ទៅ។

ក៖ ចាំហ្នឹងហើយ។

ខ៖ អត់ឃ្លានអត់អីចេះតែទៅហើយ ធ្វើម៉េចយើងវាអញ្ចឹងទៅហើយវាក្រយើងធ្វើម៉េច។

ក៖ ចាំចឹងអ៊ំពេលអ៊ំនៅពីក្មេងអ៊ំធ្លាប់មានក្តីសង្ឃឹមថាធំឡើងអ៊ំធ្វើអីគេអត់?

ខ៖ អត់ដែលធ្វើអីផង។

ក៖ មាធ្លាប់សង្ឃឹមថាធំឡើងមានចង់ធ្វើអីអត់?

ខ៖ ចិត្តញ៉ុមហោ?

ក៖ ចាំ!!

ខ៖ បើញ៉ុមអត់ចេះអក្សរបានអីធ្វើកើត បើយើងនៅជាមួយគេវាយ៉ាប់។

ក៖ តែធ្លាប់មានក្តីស្រម៉ៃអីអត់?ចង់តែធំឡើងរៀបការហើតាមដំនើរចឹងទៅ?

ខ៖ ចាំ!!រៀបការហើយចឹងបែកម៉ែមកនៅតាមប្តីមក។

កះ ចាំ!!ហ្នឹងហើយ ចឹងអ៊ំសូមប្រាប់ញ៉ុមពីជីវិតរបស់អ៊ំហាំពេលជំនាន់ប៉ុល ពតតើអ៊ំបានជួបនឹងរឿងអីគេខ្លះដែរនៅក្នុងជីវិតរបស់អ៊ំហាំ?

ខះ វេទនាណាស់ជំនាន់អាពត។

កះ អ៊ំអាចប្រាប់ដោយសង្ខេបហា?

ខះ ញ៉ុមវេទនាមែន វេទនាកាលពីជំនាន់អាពត បាយទឹកមិនដឹងឯណាឯណីទេ វេទនាណាស់ ដេកអីវាពិបាក គេអោយកាប់ជីកាប់អីអាពត វេទនាណាស់ នឹកឃើញអាពតនិយាយអត់ចង់ចេញទេញ៉ុមឆ្អែតម៉ង។

កះ ឥឡូវអ៊ំនិយាយពីពេលវេលាដែលអ៊ំពិបាកជាងគេនៅជំនាន់អាពតបន្តិចមើល?

ខះ ពិបាកជាងគេបង្អស់គឺរឿងប៉ុលពត។

កះ ម៉េចវិញ?

ខះ ពិបាករឿងបាយទឹក ហូបមិនឆ្អាយអើយ៉ាប់ណាស់!!និយាយទៅយ៉ាប់ម៉ង។

កះ ឥឡូវប៉ុណ្ណឹងសិនសង្ខេបជំនាន់ប៉ុល ពតប៉ុណ្ណឹងសិន ជំនាន់លន់ នល់អ៊ំធ្លាប់បានជួបរឿងអីគេខ្លះ ជំនាន់លន់ នល់ គេទំលាក់គ្រាប់ហាំ?

ខះ កាលហ្នឹងហោ អាកាលគេវៃចូលភ្នំពេញហ្នឹងហោ?

កះ ចាំ!!

ខះ អើរត់វេទនាដែរហ្នឹងហាំជំលៀសចេញយើងជំលៀសចេញរែកឥវ៉ាន់រែកអីចឹងទៅតាមផ្លូវតាមអីគេចឹងទៅ ជួបប្រទះនិស្សិតគេងាប់តាមផ្លូវពេញ ញ៉ុមខ្លាចអាពេលគ្រាប់ផ្លោងចូលដល់ភ្នំពេញហ្នឹងហាំ!!ជំលៀសចេញទៅមើលទៅយើងសុទ្ធដេកនៅពេញផ្លូវ ពេញវាលសុទ្ធតែអ្នកងាប់ ហើយញ៉ុមភ័យផងអីផងរត់រែកឥវ៉ានមួយអំរែក មួយអំរែកហ្នឹងរត់ដើរហ្នឹងគេដើរនឹងឯងចឹងទៅណាស់!! ទំរាំបានគេបញ្ជូនទៅ ហើយគេឡើងរទេះភ្លើងអីណាតែពីតែពាសញ៉ុមថាហ្ហូយ៉ាប់ណាស់ទំរាំគេអោយកន្លែងនៅនៅម្តុំផ្ទះយើងនេះ ជិតព្រះនេត្រព្រះយើងនេះណាស់!! គោកតាយ៉ង់ ជំនាន់អាពតញ៉ុមនៅគោកតាយ៉ង់ហើយគេជំលៀសចឹងទៅកន្លែងគេទឹមងាប់ ឈឺឡើងអស់សក់រលីង កាលហ្នឹងម៉ែញ៉ុមគាត់ទៅលេងកាលហ្នឹងស្អាត់ទៅរកគ្នានៅអាពតមួយសារទៀត ដល់ពេលញ៉ុមនៅជាមួយគាត់ ញ៉ុមក៏ឈឺ ឈឺជ្រុះសក់អស់ទៀត ញ៉ុមថាអើម៉ែអើយម៉ែយ៉ាប់ណាស់!!ក៏ដេញខ្ញុំមកវិញ ទៅ

ជួបគាត់នៅអាពតហើយហ្នឹងហាំ!! ទៅឈឺជ្រុះសក់អស់ទៀត ហើយញ៉ុមទៅនៅជាមួយគាត់ ដាំបាយទៅផ្ទះរលំកិនលើទៅប៉ាញ៉ុមនេះណាស់!!គាត់ឃើញគាត់រត់ទៅជួយ ហើយអ្នកស្រុក ហ្នឹងថាអើទៅមើលកូនផ្ទះអាលំកិនលើហើយអ្នកស្រុកកំពតហ្នឹងហាំ!! អើយញ៉ុមជួបវេទនា ណាស់!!ស្មានតែមិនបានរស់ដល់ថ្នាក់នេះទេ ផ្ទះរលំកិនលើកំពុងតែដាំបបរ បបរកាលហ្នឹង អង្ករកន្លះកំប៉ុង បបរហូបមួយគ្រួសារចឹងទៅណាស់!! មកចឹងញ៉ុមថា វេទនាណាស់ម៉ែប៉ាអើយ បានមកជួបម៉ែប៉ាមួយភ្លេត ញ៉ុមថានៅមិនបានយូរទេ ញ៉ុមថាញ៉ុមទៅវិញហើយ។

កៈ ចាំហ្នឹងហើយ ចឹងអ៊ំកាលហូបចុករបស់អ៊ំនៅក្នុងជំនាន់ប៉ុល ពតម៉េចដែរ?

ខៈ វេទនាហូបណាស់ចាប់តែកូនខ្នាត់ហូប ក៏គេរ៉ៃធ្វើបាបគ្មានអីហូបទេ តែអំបិលគ្រោះតែមួយ គ្រាប់ៗធ្វើលិតៗ វេទនាមែនញ៉ុមនឹកឃើញញ៉ុមកំសត់ និយាយទៅញ៉ុមវេទនាណាស់!! វេទនា ដល់សព្វថ្ងៃញ៉ុមនឹកឃើញថាពីអាពតញ៉ុមវេទនាញ៉ុមត្រដររស់ទំរាំញ៉ុមវេទនាប៉ុននេះញ៉ុមត្រូវ តស៊ូតទៅមុខទៀត អត់ហូបមានហូបចេះតែតស៊ូទៅមុខទៀតទៅណាស់!!យើងធ្វើម៉េចបើឆាក ជីវិតរបស់មនុស្សវាចឹងចេះតែតស៊ូទៅមុខទៀតថ្ងៃណារហូតដល់យើងដាច់ជីវិតទៅអាហ្នឹងចាំ យើងអស់ត្រឹមហ្នឹងទៅ!!

កៈ ចាំ!!ចឹងអ៊ំមានដែលធ្លាប់ឮបីរបបប៉ុល ពតថាតើគេសម្លាប់មនុស្សយ៉ាងម៉េចដែរអត់?

ខៈ អូយសាហាវណាស់!!!

កៈ ម៉េចវិញទៅអ៊ំ?

ខៈ គេបោកមនុស្សនឹងគល់ឈើគល់អី។

កៈ អ៊ំឃើញផ្ទាល់ភ្នែកទេ?

ខៈ ឃើញគេចងស្លាបសេកបណ្តើរនៅមុខខ្ញុំនឹងក៏មានដែរ ញ៉ុមភ័យណាស់!!គេអោយទៅនែ អោយទៅចាប់ដៃនែ នារី នារីបានប្តីប្រពន្ធគេហ្នឹងហាំ ទៅធ្វើមេទិញហ្នូ!!ដល់ទៅចឹងទៅគេរៀប មួយគូរៗចឹងទៅណាស់!!យើងទៅជួយគេហៅថាជួយអបអរសាទរគេ ហ្នឹងហាំ!!គេបានចាប់ដៃ គ្នាប៉ុន្មានៗគូរទេកាលហ្នឹង កាលហ្នឹង៥០គូរហើ ចាប់ជាប្តីប្រពន្ធគ្នា។

កៈ ហើយគេស្រលាញ់គ្នាអត់ឬក៏គ្រាន់តែគេហៅ?

ខៈ គេចាប់ដាក់ៗ ។

កៈ អើយដាច់ខ្យល់ហើយអ៊ំណោះ?

ខ៖ វេទនាណាស់ ចាប់ដាក់ៗកាលហ្នឹងញ៉ុមអត់ទាន់ក្រមុំទេញ៉ុមនៅរាងស្ទើរនៅឡើយប៉ុន្តែញ៉ុមនៅចងចាំញ៉ុមនៅពីក្មេងទេណាស់តែខ្ញុំគ្រាន់តែ។

ក៖ អ៊ំធ្លាប់ឃើញគេអារករនឹងផាងត្នោតអីអត់?

ខ៖ ថាវេទនាណាស់ញ៉ុមគ្រាន់តែនឹកឃើញអ្នកស្លាប់ អត់បាយអត់ទឹក ពួកក្មេងចាប់បោកហ្នឹងគ ល់ឈើ។

ក៖ ចាំអូយឡើងសាហាវម៉ងអ៊ំហេ?

ខ៖ ចាប់បោកម៉ងក្មេង ញ៉ុមបិទភ្នែកម៉ងអត់ហ៊ានមើលទេ។

ក៖ ស្លាប់ទៅ!!ហើយមូលហេតុអីបានយកក្មេងហ្នឹងទៅបោកអ៊ំ?

ខ៖ មិនដឹងទេដល់គេចាប់ខ្លះយកពីម៉ែទៅហើយខ្លះយប់ឡើងចឹងគ្នាមិនបានដេកមិនបានពួនអី ទេមករកដើររកដើររកផ្ទះឆែកឆេរមើលថា កាលហ្នឹងអ៊ីញ៉ុមប្តីគាត់ទេណាស់!!ថាប្តីមិត្តឯងទៅ ណាអស់ហើយហើយអ៊ីញ៉ុមគាត់ថាទៅព្យួរស្រែព្យួរអីឯណាអស់ហើយ ដឹងគាត់ទៅឯណាទេញ៉ុមអត់ហ៊ាននិយាយផង។

ក៖ ចាំ!!

ខ៖ ហើយញ៉ុមទៅលួចបុកស្រូវក្រោយមួយត្បាល់ប៉ុននេះ ទៅគេមកចាប់ញ៉ុម។

ក៖ ចាប់ម៉េចទៅអ៊ំ?

ខ៖ គេបំរុងមកចាប់តើ។

ក៖ ចាំ!!

ខ៖ ដល់ហើយញ៉ុមប្រកែកថាញ៉ុមអត់បានធ្វើទេ អត់ទេ ទៅបាន ពូញ៉ុមគាត់ជួយអើយកុំធ្វើបាបវាអីព្រោះអីវាអត់ដឹងអីទេ ទៅឆ្លើយថាញ៉ុមរាងឡប់ៗអីវិញទៅ ណាស់!!! បានដោះសារថាឡប់ៗ។

ក៖ ចាំ!!

ខ៖ បានគេប្រលែងញ៉ុមមកវិញហ្វូ!! ជីករណ្ដៅជីកអី ហើយចប ចបកាប់ ចបជីកអីដំបងអីគ្នាវា៤ ៥នាក់។

កៈ ចង់ចាប់អ៊ំអោយហើយ?

ខៈ គេជីករណ្តៅហើយបានយកញ៉ុមទៅទៅពូញ៉ុមគាត់មកទាន់ គាត់ជួយដោះស្រាយញ៉ុមថាអូនឯងកុំប្រកាន់អីព្រោះអីមីហ្នឹងវាឡប់ៗទេវាអត់ដឹងអីទេ ចឹងទៅណាស់!! អាពតក៏គេប្រលែងមកវិញមក ញ៉ុមថាញ៉ុមស្លាប់ថ្ងៃហ្នឹងហើយ។

កៈ ហ្នឹងហើយចឹងអ៊ំមានអារម្មណ៍ម៉េចដែរនៅពេលបានរួចផុតជីវិតពីរបបសង្គ្រាមហ្នឹងមក?

ខៈ អរគុណពូញ៉ុមដែលគាត់បានទៅជួយដោះស្រាយអរគុណរំភើបម៉ងតែឥឡូវគាត់ស្លាប់គាត់ ស្លាប់អាពតយកទៅវៃចោលវិញ។

កៈ ចំគាត់ជួយអ៊ំតែអាពតយកគាត់ទៅវៃចោលវិញ?

ខៈ ចាំកាលហ្នឹងអាចុងក្រោយទៀត គាត់ឈ្លោះគ្នាជាមួយប្តីប្រពន្ធគាត់ ។

កៈ ចាំ!!ឈ្លោះគ្នាជា មួយប្តីប្រពន្ធគាត់ទៅគេយកគាត់ទៅគាត់ថាគេថាអោយទៅស្រុកថាស្រុកកំណើតយើងនៅឯ ណាគេអោយទៅស្រុកកំណើតយើងហ្នឹងវិញហើយគាត់ក៏ទៅលាយាយញ៉ុមនេះនេះយាយទូ តនេះ។

កៈ ចាំ!!

ខៈ គាត់លាទៅគាត់ថាម៉ែអើយគេអោយញ៉ុមទៅស្រុកវិញហើយអរ ស្រាប់ទៅបាត់ស្រមោលឆឹង គេដឹងថាគេយកទៅវៃ ក្នុងត្រយូងមានរាប់ពាន់អ្នកនៅហ្នឹងឯងពូញ៉ុមជួយរំដោះញ៉ុមចេញមកញ៉ុមអរ ញ៉ុមអរគុណគាត់ណាស់ញ៉ុមថា ហ្អូកុំបានមារឯងទេកុំអីខ្ញុំយ៉ាប់ហើយ។

កៈ ហ្នឹងហើយ។

ខៈ គេយកញ៉ុមទៅវៃចោលហើយ។កៈ ចាំ!!ខៈ ជីករណ្តៅជីកអីហើយហើយណាស់!!

កៈ ចាំចឹងអ៊ំសំរប់សំនួរមួយនេះគឺជាសំណួរមួយចុងក្រោយហាំ!!អ៊ំមានអីផ្តែផ្តាំទៅកាន់កូនចៅអ៊ំជំនាន់ក្រោយដែលស្តាប់ឮសំដីរបស់អ៊ំ អ៊ំមានអីចង់នែនាំគាត់អីអត់?

ខៈ វេទនា ចង់ផ្តែផ្តាំទៅកាន់កូនចុងក្រោយហ្នឹងហោ?កៈ ចាំ!!ខៈ អោយកូនមានភាពតស៊ូអោយខំប្រឹងរកដើម្បីក្រពះយើងចិញ្ចឹមជីវិតយើងតទៅមុខទៀតអត់ធុត់ អត់មានស៊ីអត់មានអីអោយខំប្រឹងតស៊ូផ្តែផ្តាំកូនបានប៉ុណ្ណឹងឯង។

ក៖ ចាំអោយគាត់គេចផុតពីផ្លូវអីគេដែរអុំ?

ខ៖ ចាំ?

ក៖ អោយគាត់គេចផុតពីផ្លូវអីគេដែរ?កូនចៅជំនាន់ក្រោយរបស់អុំហាំ?

ខ៖ ឥឡូវៗនេះ?

ក៖ ចាំ!!

ខ៖ ដូចអត់មានអីផង។

ក៖ ដូចជាកូនចៅជំនាន់ៗក្រោយទៀតឥវ៉ាន់ដែរចឹងដែរហាំ?

ខ៖ ជំនាន់ៗក្រោយនេះ?

ក៖ ចាំអោយគាត់គេចផុតពីផ្លូវអីគេដែរអុំ?

ខ៖ គេចផុតពីអាគ្រឿងថ្នាំញៀនថ្នាំអីកុំអោយប៉ះពាល់។

ក៖ ចាំ!!

ខ៖ ខ្លាច សុទ្ធតែចូលអាហ្នឹងហើយសុទ្ធតែវេទនាហើយុំ

ក៖ ចាំហ្នឹងហើយ។

ខ៖ ថាវេទនាចិត្តណាស់!!កុំប្រដៅណែនាំកុំអោយចឹងយើងមិនល្អទេណាកូន។

ក៖ ចាំចឹងជៀសផុតពីអបាយមុខផ្សេងៗហ្នឹងអុំណោះ?

ខ៖ ចាំអោយគេចពីហ្នឹងអោយផុតពីខ្លួនយើង មើលទៅនិយាយអីទៅអាគ្រឿងចឹងមានផលប្រយោជន៍អីទេ បំផ្លាញជីវិតយើង។

ក៖ ចាំ!!

ខ៖ អាចសម្លាប់ម៉ែឪ។

ក៖ ហ្នឹងហើយ។

ខ៖ សេពអាគ្រឿងចឹងៗវាអត់ល្អ។

ក៖ ចាំ!!

ខ៖ ចេះតែឧស្សាហ៍ណែនាំកូនជំនាន់ក្រោយដែរនេះ អាប្រុសនេះ ប្រដៅវា។

ក៖
ចាំចឹងអរគុណច្រើនមែនទែនសំរាប់ការចូលរួមនៅក្នុងការសំភាសន៍ថ្ងៃនេះហើយអ្វីទាំងអស់ពួកយើងនឹងរៀបចំដូចជាទុកអោយកូនចៅអ៊ំជំនាន់ក្រោយបានស្តាប់តទៅមុខទៀតចឹងណា
អ៊ំចាំចឹងអរគុណច្រើនណាស់អ៊ំ!!

ខ៖ ចាំចាំ។